**ចុះគោរពឱ្យខ្ជាប់**

អាន អិម ឱប
ទីប្រឹក្សាទីពីរនៅក្នុងគណៈប្រធានយុវនារីទូទៅ

*ព្រះវរបិតាសួគ៌ពុំបានបោះបង់យើងចោលឱ្យនៅតែម្នាក់ឯង នៅអំឡុងការសាកល្បងក្នុងជីវិតរមែងស្លាប់របស់យើងទេ ។ ទ្រង់បានប្រទានដល់យើងរួចជាស្រេចនូវឧបករណ៍សុវត្ថិភាព ដែលយើងត្រូវការដើម្បីត្រឡប់ទៅរកទ្រង់វិញដោយ ជោគជ័យ ។*

ជាច្រើនឆ្នាំកន្លងទៅ ខ្ញុំមានចំណាប់អារម្មណ៍នឹងអត្ថបទខ្លីៗមួយដែលបានចុះនៅក្នុងសារព័ត៌មានក្នុងមូលដ្ឋាន ហើយខ្ញុំក៏បានចងចាំអត្ថបទនោះ ចាប់ពីពេលនោះមក ។ វាបានលើកឡើងថា : "មានមនុស្សចំនួនបួននាក់បានស្លាប់ ហើយពួកកម្មករប្រាំពីរនាក់ទៀតត្រូវបានសង្គ្រោះ បន្ទាប់ពីការ ការតោងស្ពានដែលមានកំពស់ 38 ម៉ែត្រ អស់ជាងមួយម៉ោងមក នៅផ្លូវខាថារីន ក្នុងទីក្រុង អង់តារីយ៉ូ [ប្រទេសកាណាដា] ដោយសារអន្ទាវដែលជាន់ឈរធ្វើការនោះបានដួលរលំ..." ("News Capsules" *Deseret News* ថ្ងៃទី 9 ខែ មិថុនា ឆ្នាំ 1993 ទំព័រ A2) ។

ខ្ញុំបាន ហើយនៅតែមានភាពស្ងប់ស្ងែងចំពោះព័ត៌មានខ្លីនេះ ។ ភ្លាមៗ ក្រោយពីអានព័ត៌មាននេះ ខ្ញុំបានទូរស័ព្ទទៅគ្រួសារមិត្តភក្តិខ្ញុំដែលបានរស់នៅផ្លូវខាថារីន ។ គាត់បានពន្យល់ថា ពួកកម្មករបានលាបថ្នាំនៅស្ពានហ្គាឌិនស៊ីធីស្កាយវេ អស់ជិតមួយឆ្នាំមកហើយ ហើយរយៈពេលពីរសប្តាហ៍បន្ទាប់ពីបញ្ចប់គំរោងនេះ នៅពេលគ្រោះថ្នាក់កើតឡើង ។ បន្ទាប់ពីឧបទ្ទវហេតុ គេចោទសួរទៅពួកមន្ត្រីថាហេតុអ្វីបុរសទាំងនេះពុំមានឧបករណ៍សុវត្ថិភាព ។ ចម្លើយឆ្លើយ យ៉ាងសាមញ្ញថា: ពួកគេមានឧបករណ៍ តែពួកគេជ្រើសរើសមិនពាក់ឧបករណ៍នោះ ។ បន្ទាប់ពីកាបាក់ដ៏គ្រោះថ្នាក់ ពួកអ្នកដែលនៅមានជីវិតបានតោងនឹង គែមដែលធ្វើពីដែកថែបដែលមានប្រវែង 2.5 សង់ទីម៉ែត្រ ហើយឈរនៅលើ គែមដែលធ្វើអំពីដែកថែបមានកំពស់ 20 សង់ទីម៉ែត្រអស់រយៈពេលមួយម៉ោង រហូតដល់ក្រុមសង្គ្រោះទៅដល់ ។ ជនរងគ្រោះដែលនៅរស់ម្នាក់ បានរៀបរាប់ថា នៅពេលគាត់កំពុងតោងស្ពាន គាត់បានគិតអំពីក្រុម-គ្រួសារគាត់យ៉ាងច្រើន ។ គាត់បាននិយាយថា "ខ្ញុំមានអំណរគុណដល់ព្រះអម្ចាស់ដែលខ្ញុំមានវត្តមាននៅទីនេះ នៅថ្ងៃនេះ...។ ខ្ញុំសូមជំរាបអ្នកថា ហេតុការណ៍នោះគួរឱ្យភ័យខ្លាចណាស់" ("Skyway Horror" ដោយ Rick Bogacz, *The Standard* ថ្ងៃទី 9 ខែ មិថុនា ឆ្នាំ 1993) ។

មានមេរៀនជាច្រើនដែលត្រូវរៀន ហើយការប្រៀបធៀបជាច្រើនត្រូវធ្វើឡើង ចេញអំពីហេតុការណ៍នេះ ។ ដោយសារ ពួកយើងភាគច្រើនពុំដែលប្រឈមមុខនឹងសោកនាដកម្មបែបនេះ ដូចជាស្ថានភាពជីវិតឬសេចក្តីស្លាប់ ដែលយើងជាច្រើន មានអារម្មណ៍ថាយើងកំពុងតែឆ្លងកាត់ពេលវេលាដ៏គួរឱ្យភ័យខ្លាចមួយ នៅក្នុងជីវិតរបស់យើងផ្ទាល់ ។

យើងក៏អាចនឹងទទួលអារម្មណ៍ថា យើងកំពុងតែកាន់អ្វីមួយដែលគែមស្ពានដែកប្រមាណជាជាងពីរសង់ទីម៉ែត្រដែរ ។ ជីវិតរមែងស្លាប់របស់យើងគឺពុំងាយស្រួលឡើយ ហើយវាក៏ពុំខ្លីដែរ ។ យើងត្រូវបានប្រទានពរឱ្យមកកាន់ផែនដីនេះ ហើយទទួលយករូបកាយរមែងស្លាប់ ។ ជីវិតនេះ គឺជាឱកាសរបស់យើងដើម្បីបង្ហាញពីខ្លួនឯង និងអនុវត្តសិទ្ធិជ្រើសរើសរបស់យើង (សូមមើល អ័ប្រាហាំ 3:25) ។ យើងអាចជ្រើសរើសដើរតាមផែនការសង្គ្រោះ (សូមមើល យ៉ារ៉ុម 1:2 អាលម៉ា 42:5 ម៉ូសេ 6:62)និងផែនការ

ប្រោសលោះ (សូមមើល យ៉ាកុប 6:8 អាលម៉ា 12:25; 42:11 )ដ៏នៅអស់កល្បជានិច្ចរបស់ព្រះវរបិតាសួគ៌យើង ឬយើងអាចព្យាយាមស្វែងរកផ្លូវផ្ទាល់ខ្លួនរបស់យើងក៏បាន។ យើងអាចជាមនុស្សដែលគោរពប្រតិបត្តិដល់ព្រះបញ្ញត្តិរបស់ទ្រង់ ឬយើងបដិសេធព្រះបញ្ញត្តិទាំងនោះ ហើយប្រឈមមុខនឹងលទ្ធផលនឹងកើតមានឡើងក៏បាន។

ដោយសារតែហេតុនេះ នោះយើងក៏មាននូវការពិពណ៌នាពីការងារ និងកាតព្វកិច្ចដ៏គ្រោះថ្នាក់ផងដែរ។ យើងត្រូវប្រឈមមុខនឹងឧបសគ្គជាច្រើន។ យើងអាចជួបប្រទះនឹងភាពឯកកោ ការបាត់បង់មិត្តភាព ការបាត់ទំនុកចិត្ត ការល្បួង ការញៀន រូបកាយពិការ ឬការបាត់បង់ការងារដែលត្រូវការយ៉ាងខ្លាំង។ យើងអាចប្រឈមមុខនឹងអារម្មណ៍នៃ ការបាក់ទឹកចិត្ត ពីព្រោះតែសេចក្តីសង្ឃឹមសុចរិតរបស់យើង និងសុបិនមិនសមតាមបំណងរបស់យើង។ យើងអាចសង្ស័យនឹងសមត្ថភាពរបស់យើង និងខ្លាចចំពោះការបរាជ័យ ទោះបីជាមុខងារនៅក្នុងសាសនាចក្រ និងការងារក្នុងគ្រួសាររបស់យើងក្តី។ ការប្រឈមមុខ និងគ្រោះថ្នាក់ដែលយើងរស់នៅសព្វថ្ងៃនេះ រួមទាំង ការស៊ូទ្រាំ នឹងអំពើបាបរបស់សង្គម ដែលត្រូវបាន ព្យាករដោយពួកព្យាការីពីបុរាណ និងកំពុងរស់នៅ។ ទាំងនេះ គឺគ្រាន់តែជា ភាពមិនទៀងទាត់ និងពិត ដូចជាការតក់ស្លុត នៃការធ្លាក់ពីកំពស់ 38 ម៉ែត្រ ដែលបណ្តាលឱ្យស្លាប់ដោយសារស្ថានមានកំពស់ខ្ពស់។

ជីវិតរបស់ខ្ញុំពុំឥតខ្ចោះទេ។ ខ្ញុំបានប្រឈមមុខនឹងបញ្ហាដូចគ្នាជាច្រើន។ យើងទាំងអស់គ្នាប្រឈមមុខនឹងបញ្ហាទាំងនេះ។ ខ្ញុំដឹងថាការល្បួងរបស់មារសត្រូវ និងភាពលំបាកក្នុងជីវិតរមែងស្លាប់ គឺកើតមាន និងឡោមព័ទ្ធយើងជានិច្ច។ ខ្ញុំឯកភាពនឹង ពាក្យរបស់កម្មករដែលត្រូវបានសង្គ្រោះពីគ្រោះថ្នាក់ ដោយការកាន់នឹងតែមដែលធ្វើអំពីដែកថែបៈ "ខ្ញុំសូមជំរាបអ្នកថា ហេតុការណ៍នោះ [គឺ] គួរឱ្យភ័យខ្លាចណាស់"។

ទោះជាយ៉ាងណាក្តី ការកត់ត្រាចំណាំគឺជារឿងសំខាន់ នៅក្នុងបទគម្ពីរមានដំណើររឿងពីរបីអំពីបុគ្គលដែលបានរស់នៅក្នុងសុភមង្គលដ៏រីករាយ ហើយពុំជួបប្រទះនូវការផ្ទុយគ្នាឡើយ។ យើងរៀន ហើយរីកចំរើនទៅមុខ តាមរយៈការយកឈ្នះលើឧបសគ្គដោយសេចក្តីជំនឿ តស៊ូ និងសេចក្តីសុចរិតផ្ទាល់ខ្លួន។ ខ្ញុំត្រូវបានពង្រឹងដោយទំនុកចិត្តដ៏គ្មានព្រំដែនរបស់ប្រធានថូម៉ាស អេស ម៉នសុន ចំពោះព្រះវរបិតាសួគ៌ និងចំពោះយើង។ លោកបានមានប្រសាសន៍ថាៈ "សូមចងចាំថា អ្នកមាន ពរជ័យរបស់ព្រះវរបិតា [សួគ៌] នៅក្នុងកិច្ចការនេះ។ ទ្រង់ពុំបានហៅអ្នកឱ្យដើរនៅក្នុងស្ថានភាពរបស់អ្នក តែម្នាក់ឯង ដោយគ្មានការដឹកនាំទៅរកឱកាសនោះទេ។ ម្យ៉ាងវិញទៀត ទ្រង់ជ្រាបនូវជំនាញរបស់អ្នក ទ្រង់ជ្រាបនូវការពុះពារ របស់អ្នក ហើយទ្រង់នឹងផ្លាស់ប្តូរភាពមិនគ្រប់លក្ខណៈរបស់អ្នកឱ្យទៅជាកម្លាំង។ ទ្រង់បានសន្យាថាៈ 'យើងនឹងទៅពីមុខអ្នក។ យើងនឹងនៅខាងស្តាំដៃអ្នក ហើយខាងឆ្វេងដៃអ្នក ហើយព្រះវិញ្ញាណរបស់យើងនឹងសណ្ឋិតនៅក្នុងដួងចិត្តរបស់អ្នក ហើយពួកទេវតារបស់យើងនៅព័ទ្ធជុំវិញអ្នក ដើម្បីទ្រអ្នកឡើង'"។ ("Sugar Beets and the Worth of a Soul" *Liahona* ខែ កក្កដា ឆ្នាំ 2009, 3--4)។

ព្រះវរបិតាសួគ៌ពុំបានបោះបង់យើងចោលឱ្យនៅតែម្នាក់ឯង នៅអំឡុងការសាកល្បងក្នុងជីវិតរមែងស្លាប់របស់យើងទេ។ ទ្រង់បានប្រទានដល់យើងរួចជាស្រេចនូវឧបករណ៍សុវត្ថិភាព ដែលយើងត្រូវការដើម្បីត្រឡប់ទៅរកទ្រង់វិញដោយជោគជ័យ។ ទ្រង់បានប្រទាននូវការអធិស្ឋានផ្ទាល់ខ្លួន ព្រះគម្ពីរ ពួកព្យាការីដែលនៅរស់ និងព្រះវិញ្ញាណបរិសុទ្ធដឹកនាំយើង។ ពេលខ្លះ ការប្រើប្រាស់

ឧបករណ៍នេះហាក់ដូចជាបន្ទុកល្វង់ខ្លៅ និងមិនទំនើបទាល់តែសោះ ។ ការប្រើប្រាស់ឧបករណ៍ទាំងនេះវាតម្រូវឱ្យមានការឧស្សាហ៍ព្យាយាម និងការតស៊ូ ។ ប៉ុន្តែខ្ញុំជ្រើសរើសប្រើប្រាស់ឧបករណ៍នេះ ។ យើងទាំងអស់គ្នាត្រូវតែជ្រើសរើសប្រើប្រាស់ឧបករណ៍នេះ ។

ក្នុងបទគម្ពីរ យើងរៀនអំពីបំណែកគន្លឹះនៃឧបករណ៍សុវត្ថិភាពមួយទៀត---គឺជា"ដំបងដែក" ។ ពួកសិស្សរបស់ព្រះអង្គសង្គ្រោះរបស់យើង គឺត្រូវបានអញ្ជើញឱ្យកាន់ដំបងដែកនេះឱ្យជាប់ ក្នុងការស្វែងរកផ្លូវសុវត្ថិភាពរបស់ពួកគេទៅរកជីវិតដ៏នៅអស់កល្បជានិច្ច ។ ខ្ញុំកំពុងនិយាយអំពីការនិមិត្តរបស់លីហៃពីដើមឈើជីវិតដែលមាននៅក្នុងព្រះគម្ពីរមរមន ។

តាមរយៈវិវរណៈដ៏ទេវភាពផ្ទាល់ខ្លួន លីហៃជាព្យាការីក្នុងព្រះគម្ពីរមរមន និងនីហ្វៃកូនប្រុសរបស់លោក ពួកគាត់ម្នាក់ៗត្រូវបានបង្ហាញនូវការនិមិត្តពីស្ថានភាពនៃការសាកល្បងក្នុងជីវិតរមែងស្លាប់ ហើយការសាកល្បងនេះមាននូវគ្រោះថ្នាក់ផងដែរ ។ លីហៃនិយាយថាៈ "ហើយហេតុការណ៍បានកើតឡើងថា មានអ័ព្ទនៃសេចក្ដីងងឹតបានផុសឡើង មែនហើយ គឺជាអ័ព្ទនៃសេចក្ដីងងឹតដ៏ធំដរាបដល់ធ្វើឱ្យពួកគេដែលបានដើរនៅលើផ្លូវនោះត្រូវធ្លាក់វង្វេង ខ្ចាត់ខ្ចាយបាត់អស់ទៅ" (នីហ្វៃទី 1 8:23) ។ មែនហើយ "ឪពុកខ្ញុំ [ក៏] បានឃើញមនុស្សទាំងហ្វូងៗប្រជ្រៀតទៅមុខ ហើយពួកគេ បានមកកាន់ចុងដំបងដែក ហើយពួកគេបានប្រជ្រៀតគ្នាទៅមុខ ដោយកាន់ដំបងដែកយ៉ាងខ្ជាប់ជានិច្ច រហូតដល់ពួកគេ បានមកដល់ ហើយដួលចុះ ហើយបរិភោគផ្លែឈើនោះទៅ" (នីហ្វៃទី 1 8:30) មានន័យថាជាដើមឈើជីវិត ។

យើងរៀនចេញពីការនិមិត្តរបស់លីហៃថា យើងត្រូវតែប្រកាន់ខ្ជាប់នូវផ្លូវដែលមានសុវត្ថិភាព ដែលជាផ្លូវដំបងដែកនេះ ដែលមាននៅតាមផ្លូវត្រង់ និងចង្អៀតនេះ ហើយតោងយ៉ាងជាប់ រហូតដល់យើងឈោងទៅដល់គោលដៅពិត នៃជីវិត ដ៏នៅអស់កល្បជានិច្ចរបស់យើង ជាមួយនឹងព្រះវរបិតាសួគ៌របស់យើង ។ នីហ្វៃសន្យាថា អ្នកទាំងឡាយដែលកាន់ខ្ជាប់ទៅនឹងដំបងដែក " នោះនឹងមិនត្រូវវិនាសឡើយ សូម្បីតែការល្បួងទាំងឡាយ និងព្រួញភ្លើងទាំងឡាយរបស់ មារសត្រូវក៏មិនអាចឈ្នះលើគេ ដល់ទៅធ្វើឱ្យគេខ្វាក់ដើម្បីនាំគេទៅឯសេចក្ដីបំផ្លិចបំផ្លាញបានដែរ" (នីហ្វៃទី 1 15:24) ។

ខ្ញុំសូមអញ្ជើញអ្នកឱ្យអានឡើងវិញម្ដងទៀត នូវដំណើររឿងទាំងមូលអំពីការនិមិត្តដ៏បំផុសគំនិតនេះ ។ ចូរសិក្សាដំណើរ រឿងនេះ ចូរពិចារណាអំពីដំណើររឿងនេះ ចូរអនុវត្តដំណើររឿងនេះនៅក្នុងជីវិតប្រចាំថ្ងៃរបស់អ្នក ។ នៅក្នុងពាក្យពេចន៍ សម័យទំនើប យើងអាចហៅបានថា យើងត្រូវបានអញ្ជើញឱ្យ "ចាប់យ៉ាងណែន" ។ យើងត្រូវតែកាន់ឱ្យជាប់ទៅនឹង ដំបងដែក ពុំលែងឡើយ ។

ប្រធាន ហារូល ប៊ី លី ជាព្យាការី នៅពេលខ្ញុំមានវ័យជំទង់ បានបង្រៀនថា "វត្ថុដ៏ចាំបាច់បំផុតមួយនៅក្នុងគ្រានៃភាពច្របូកច្របល់ និងភាពស្មុគស្មាញ ជាពេលដែលយុវជនយុវនារី និងយុវវ័យជំទង់ទាំងឡាយ កំពុងស្វែងរកយ៉ាងខ្លាំងសំរាប់ចម្លើយទៅនឹងបញ្ហានានា ដែលធ្វើឱ្យមនុស្សលោករងទុក្ខ នោះគឺការមាន 'ដំបងដែក' មួយជាមាគ៌ាសុវត្ថិភាពនៅលើផ្លូវទ្រង់ឆ្ពោះទៅកាន់ជីវិតដ៏នៅអស់កល្បជានិច្ច នៅក្នុងចំណោមផ្លូវចម្លែក និងទុច្ចរិតដែលនឹងដឹកនាំទៅរកការបំផ្លិចបំផ្លាញ និងធ្វើឱ្យខូចខាតដល់អ្វីទាំងឡាយដែល 'ប្រកបដោយគុណធម៌ គួរឱ្យស្រឡាញ់ ឬឈ្មោះល្អ'" ("The Iron Rod" *Ensign* ខែ មិថុនា ឆ្នាំ 1971 ទំព័រ 7) ។

ការដកស្រង់នេះគឺទាក់ទងទៅនឹងភាពវ័យជំទង់របស់ខ្ញុំ ហើយវាប្រហែលជាទាក់ទងនឹងរឿងសព្វថ្ងៃនេះផងដែរ។ ពាក្យសម្ដីរបស់ព្យាការីបានព្រមាន បង្រៀន និងជំរុញចំពោះសេចក្ដីពិត មិនថាពួកគាត់បានមានប្រសាសន៍កាលពី 600 ឆ្នាំមុនគ.ស. ឆ្នាំ 1971 ឬឆ្នាំ 2009 នោះទេ។ ខ្ញុំសូមលើកទឹកចិត្តអ្នកឱ្យត្រៀមត្រាប់ស្ដាប់ ហើយជឿ ព្រមទាំងធ្វើតាមពាក្យសម្ដីដ៏បំផុសគំនិតនៃអស់អ្នកដែលត្រូវបានគាំទ្រឱ្យធ្វើជាព្យាការី និងជាអ្នកទទួលវិវរណៈ។

ការតោងឱ្យជាប់ទៅនឹងដំបងដែកពុំមែនជាការងាយស្រួលជានិច្ចកាលនោះទេ។ យើងអាចបោះបង់ចោលដោយសារតែ សម្ពាធពីមិត្តភក្តិ ឬសេចក្ដីឆ្មើងឆ្មៃ ដោយគិតថា យើងអាចស្វែងរកផ្លូវត្រឡប់ទៅវិញ---នៅពេលក្រោយ។ នៅពេលយើងធ្វើដូច្នោះ យើងបានបោះបង់ចោលឧបករណ៍សុវត្ថិភាពរបស់យើង។ នៅក្នុងការនិមិត្តរបស់លីហៃ លោកបានឃើញ មនុស្សជាច្រើនដែលបោះបង់ចោលដំបងដែក។ នីហ្វៃបានមានប្រសាសន៍ថាៈ "មានមនុស្សជា ច្រើនវង្វេងបាត់ពីភ្នែកលោក ដោយដើរសោត់ទៅលើផ្លូវចម្លែកៗទាំងឡាយ" (នីហ្វៃទី 1 8:32)។ នៅក្នុងគ្រាដ៏ លំបាកនៅក្នុងជីវិតរបស់ យើង យើងក៏អាចឃើញថាខ្លួនឯងក៏ "ដើរសោត់ទៅលើផ្លូវចម្លែកៗទាំងឡាយ" ដែរ។ ខ្ញុំសូមបញ្ជាក់ដល់អ្នកថា ការស្វែងរកផ្លូវរបស់យើងត្រឡប់ទៅវិញ គឺអាចរកឃើញជានិច្ច។ តាមរយៈការប្រែចិត្ត ដែលអាចធ្វើឱ្យដំណើរការបាន តាមរយៈការពលិកម្មដ៏ធួនពីព្រះអង្គសង្គ្រោះ ព្រះយេស៊ូវគ្រីស្ទ នោះយើងអាចទទួលមកវិញបាន ហើយធ្វើការតាំងចិត្ត ជាថ្មីចំពោះការតោងយ៉ាងជាប់ទៅនឹងដំបងដែក ហើយទទួលបាននូវសេចក្ដីណែនាំដែលពោរពេញដោយក្ដីស្រឡាញ់ពីព្រះវរបិតាសួគ៌ម្ដងទៀត។ ព្រះអង្គសង្គ្រោះបានអញ្ជើញដោយបើកចំហ ចំពោះយើងឱ្យៈ ប្រែចិត្ត ប្រកាន់ខ្ជាប់ និងកុំបោះបង់ចោលឡើយ។

ដូចជានីហ្វៃផងដែរ ខ្ញុំសូមទូន្មានដល់អ្នកដោយអស់ពីកម្លាំងនៃដួងព្រលឹងខ្ញុំថា អ្នកនឹង"ស្ដាប់បង្គាប់តាមព្រះបន្ទូលនៃព្រះ ហើយចងចាំ និងកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ជានិច្ច នៅគ្រប់ការណ៍ទាំងអស់" (នីហ្វៃទី 1 15:25)។ សូមប្រើប្រាស់ឧបករណ៍សុវត្ថិភាពដែលទ្រង់បានប្រទានឱ្យអ្នក។ សូមប្រកាន់ខ្ជាប់ ហើយជឿថា ព្រះវរបិតាសួគ៌នឹងប្រទានពរដល់អ្នកសំរាប់ការព្យាយាមរបស់អ្នក។

ខ្ញុំដឹងថា ដំណឹងល្អដែលបានស្ដារឡើងវិញ គឺពិត ហើយខ្ញុំដឹងថា យើងទាំងអស់គ្នាត្រូវបានដឹកនាំដោយព្យាការីនៃព្រះដែលនៅរស់ គឺប្រធាន ថូម៉ាស អេស ម៉នសុន។ កាលដែលបានធ្វើជាកូនស្រីរបស់លោក វាជាអភ័យឯកសិទ្ធដ៏អស្ចារ្យចំពោះរូបខ្ញុំ។ ខ្ញុំស្រឡាញ់ឪពុកម្ដាយរបស់ខ្ញុំខ្លាំងណាស់។

នៅល្ងាចមួយ ខ្ញុំមានអារម្មណ៍ថាបាក់ទឹកចិត្តបន្ដិច ហើយបាននិយាយថាៈ "អ៊ូ! លោកប៉ា ពរជ័យដែលយើងទទួលបាន ក្នុងនាមជាសមាជិកនៃសាសនាចក្រ និងពរជ័យដែលបានសន្យានៅក្នុងព្រះវិហារបរិសុទ្ធគឺអស្ចារ្យណាស់ *ប្រសិនបើ យើងគ្រាន់តែយល់ព្រម ហើយជ្រើសរើសធ្វើតាមពរជ័យទាំងនោះ"*។ លោកបានឆ្លើយមកវិញ ដោយពុំស្ទាក់ស្ទើរថា "អាន ពរជ័យទាំងនោះគឺជាអ្វីៗគ្រប់យ៉ាង"។

ចូរឱ្យយើង *តោងឱ្យជាប់* ទៅនឹងសេចក្ដីពិតដ៏នៅអស់កល្បជានិច្ចនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ពីព្រោះពរជ័យទាំងនោះគឺពិតជា "អ្វីៗគ្រប់យ៉ាង" គឺជាការអធិស្ឋានដ៏ស្មោះសរបស់ខ្ញុំ។ នៅក្នុងព្រះនាម នៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន។